# ផលប៉ះពាល់ផ្នែកច្បាប់នៅលើសេរីភាពខាងការបញ្ចេញមតិក្នុងយុគសម័យឌីជីថល

## ខ្លឹមសារសង្ខេប

បច្ចុប្បន្ន យើងអនុវត្តសិទ្ធិសេរីភាពខាងការបញ្ចេញមតិនៅលើប្រព័ន្ធអ៊ីនធឺណិតច្រើនស្ទើរតែស្មើនឹងការបញ្ចេញមតិដោយផ្ទាល់។ ការបង្ហោះសារ ការបញ្ចេញមតិ ការចែករំលែក និងការចុចចូលចិត្តនៅលើបណ្ដាញទំនាក់ទំនងសង្គមសុទ្ធតែជាមធ្យោបាយដែលយើងអនុវត្តសិទ្ធិនេះតាមបែបឌីជីថល។

ដូចដែលបានបង្ហាញនៅក្នុងឯកសារវិភាគផ្លូវច្បាប់ថ្មីរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា បច្ចុប្បន្ននេះមានសេចក្ដីព្រាងច្បាប់មួយចំនួនដែលអាចនឹងប៉ះពាល់ជាអវិជ្ជមានដល់សិទ្ធិសេរីភាពខាងការបញ្ចេញមតិតាមប្រព័ន្ធឌីជីថល។ ប្រសិនជាអនុម័តច្បាប់ទាំងនេះនឹងបន្ថែមទៅលើបទប្បញ្ញត្តិច្បាប់ជាធរមាននានា ដែលត្រូវបានរាជរដ្ឋាភិបាលកម្ពុជាប្រើប្រាស់រួចជាស្រេចដើម្បីរឹតត្បិតសិទ្ធិនេះ។

## នេះគឺជាចំណុចសំខាន់ៗដែលគួរយល់ដឹង៖

សិទ្ធិសេរីភាពខាងការបញ្ចេញមតិ ត្រូវបានធានាតាមមាត្រា ១៩ នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលប្រទេសកម្ពុជាបានផ្ដល់សច្ចាប័ននៅឆ្នាំ១៩៩២។ សិទ្ធិនេះក៏ត្រូវបានធានាផងដែរនៅក្នុងមាត្រា ៤១ និងមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

**ការរឹតត្បិតសិទ្ធិនេះអាចធ្វើបាន ប៉ុន្តែលុះណាតែស្របទៅនឹង «ការធ្លឹងថ្លែងបីចំណុច» តែប៉ុណ្ណោះ។ យោងតាមគោលការណ៍នេះ ការរឹតត្បិតចាំបាច់ត្រូវតែ៖**

១. តើការរឹតត្បិតនោះមានចែងនៅក្នុងច្បាប់ដែរឬទេ?
២. តើវាមានគោលបំណងស្របច្បាប់ដែរឬទេ?
៣. តើវាមានភាពចាំបាច់ និងសមាមាត្រដែរឬទេ? ការរឹតត្បិតនោះមិនត្រូវអនុវត្តលើសពីកម្រិតដែលចាំបាច់បំផុត ដើម្បីសម្រេចបាននូវគោលបំណងស្របច្បាប់នោះឡើយ។

**ស្កេនដើម្បីអានឯកសារវិភាគច្បាប់**

សម្រាប់ព័ត៌មានបន្ថែម សូមផ្ញើអ៊ីមែលមកកាន់៖ info@cchrcambodia.org
អាសយដ្ឋាន៖ ផ្ទះលេខ ៧៩៨ ផ្លូវលេខ ៩៩ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរសព្ទ៖ +៨៥៥ (០) ២៣ ៧២ ៦៩ ០១

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

CC BY NC SA

ខែវិច្ឆិកា ឆ្នាំ២០២៥

# ច្បាប់ជាធរមានមួយចំនួន ត្រូវបានប្រើប្រាស់ដើម្បីរឹតត្បិតសិទ្ធិសេរីភាពខាងការបញ្ចេញមតិតាមប្រព័ន្ធអ៊ីនធឺណិតក្នុងលក្ខខណ្ឌមិនសមាមាត្រ៖

## ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា:

- មាត្រា ៣០៥៖ បទបរិហារកេរ្តិ៍ជាសាធារណៈ
- មាត្រា ៤៩៤ និង ៤៩៥៖ បទញុះញង់
- មាត្រា ៤៣៧-ស្ទួន៖ បទប្រមាថចំពោះអង្គព្រះមហាក្សត្រ
- មាត្រា ៣០៧៖ បទប្រមាថជាសាធារណៈ
- មាត្រា ៥២៣៖ បទធ្វើឱ្យបាត់ជំនឿលើសេចក្តីសម្រេចរបស់តុលាការ
- មាត្រា ៥០២៖ បទប្រមាថ
- មាត្រា ៤២៥៖ បទក្លែងព័ត៌មាន

## ច្បាប់ស្តីរបបសារព័ត៌មាន

- មាត្រា ១១៖ ប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ
- មាត្រា ១២៖ ប៉ះពាល់ដល់សន្តិសុខជាតិ និងស្ថិរភាពនយោបាយ
- មាត្រា ១៣៖ ការផ្សព្វផ្សាយ ឬការផលិតឡើងវិញនូវព័ត៌មានមិនពិត ដែលធ្វើឱ្យអាប់ឱនកិត្តិយស ឬប្រមាថដល់ស្ថាប័នជាតិ

## ធម្មនុញ្ញវិជ្ជាជីវៈសារព័ត៌មាន

- មិនមានឃ្លាបញ្ជាក់ពីការអនុគ្រោះសម្រាប់ផលប្រយោជន៍សាធារណៈ
- ហាមឃាត់ការផ្សព្វផ្សាយមាតិកាដែល«ប៉ះពាល់ដល់វប្បធម៌ ប្រពៃណី និងទំនៀមទម្លាប់ល្អរបស់ជាតិ»
- មើលទៅហាក់ដូចជារឹតត្បិត ជាជាងការផ្តល់លទ្ធភាព ឱ្យអ្នកសារព័ត៌មានបំពេញការងាររបស់ពួកគេ

## ច្បាប់ស្តីពីទូរគមនាគមន៍ (ឆ្នាំ២០១៥) និងប្រកាសអន្តរក្រសួងលេខ ១៧០ ស្តីពី ការគ្រប់គ្រងការផ្សព្វផ្សាយតាមគេហទំព័រ និងបណ្តាញទំនាក់ទំនងសង្គម ដែលដំណើរការតាមប្រព័ន្ធអ៊ីនធឺណិតនៅព្រះរាជាណាចក្រកម្ពុជា (ឆ្នាំ២០១៨)

- ប្រការ ៨ (ក)៖បង្កចលាចលក្នុងសង្គម
- ប្រការ៦(គ)ផ្សព្វផ្សាយព័ត៌មានដោយចេតនាដើម្បីបង្កចលាចលសង្គមដែលធ្វើឱ្យអន្តរាយដល់សេដ្ឋកិច្ចជាតិ
- ប្រការ៦(គ) និងប្រការ៨(ក)ផ្សព្វផ្សាយព័ត៌មានធ្វើឱ្យអន្តរាយដល់វិស័យការពារជាតិ សន្តិសុខជាតិ ទំនាក់ទំនងជាមួយប្រទេសដទៃ សណ្តាប់ធ្នាប់សាធារណៈ វប្បធម៌ និងប្រពៃណីជាតិ
- ប្រការ ៧ (គ)៖ ផ្សព្វផ្សាយខ្លឹមសារល្មើសច្បាប់ដែលមានលក្ខណៈញុះញង់ បំបែកបំបាក់សាមគ្គី ការរើសអើង ចេតនាបង្កចលាចល ដែលអាចបណ្តាលឱ្យអន្តរាយដល់សន្តិសុខជាតិ ផលប្រយោជន៍សាធារណៈ និងសណ្តាប់ធ្នាប់សង្គម

## អនុក្រឹត្យស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិ

- មាត្រា ៦ អនុញ្ញាតឱ្យទប់ស្កាត់ ឬផ្តាច់ការតភ្ជាប់ ឬខ្លឹមសារណាមួយនៅលើប្រព័ន្ធអ៊ីនធឺណិត ដែលត្រូវបានចាត់ទុកថា «ប៉ះពាល់ដល់សន្តិសុខ ចំណូលជាតិ សណ្តាប់ធ្នាប់សង្គម សេចក្តីថ្លៃថ្នូរ វប្បធម៌ ប្រពៃណី និងទំនៀមទម្លាប់»។
- មាត្រា ១៤ អនុញ្ញាតឱ្យមានការតាមដានសកម្មភាពលើអ៊ីនធឺណិត និងការរៀបចំកំណត់ត្រានៃអាសយដ្ឋានអាយភីដែលបានបែងចែក

សម្រាប់ព័ត៌មានបន្ថែម សូមផ្ញើអ៊ីមែលមកកាន់៖ info@cchrcambodia.org
អាសយដ្ឋាន៖ ផ្ទះលេខ ៧៩៨ ផ្លូវលេខ ៩៩ សង្កាត់បឹងត្រពែក ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរសព្ទ៖ +៨៥៥ (០) ២៣ ៧២ ៦៩ ០១

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

CC BY NC SA

ខែវិច្ឆិកា ឆ្នាំ២០២៥

# បន្ថែមលើច្បាប់ និងបទប្បញ្ញត្តិជាធរមាន ក៏នៅមានសេចក្តីព្រាងច្បាប់មួយចំនួនដែលមានការរឹតត្បិតលើសិទ្ធិសេរីភាពខាងការបញ្ចេញមតិ និងសិទ្ធិឯកជនភាពផងដែរ៖

## សេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យា

- មាត្រា ៤២ ផ្តន្ទាទោសពន្ធនាគារចាប់ពីមួយខែ ដល់ពីរឆ្នាំចំពោះបុគ្គលដែលត្រូវបានរកឃើញថាមានទោសក្នុងការបង្កដោយចេតនានូវ"បង្កការបំភិតបំភ័យ គំរាមកំហែង ការរំលោភបំពានដល់អ្នកដទៃតាមមធ្យោបាយពាក់ព័ន្ធនឹងបច្ចេកវិទ្យា
- មាត្រា៤៣ រួមបញ្ចូលទាំងទោសដាក់ពន្ធនាគារចំពោះបទល្មើស «បរិហារកេរ្តិ៍ជាសាធារណៈ» ដែលផ្ទុយទៅនឹងក្រមព្រហ្មទណ្ឌ មាត្រា ៣០៥
- មាត្រា៤៤ ផ្តន្ទាទោសដាក់ពន្ធនាគារពីមួយខែទៅប្រាំមួយខែចំពោះបុគ្គលដែលត្រូវបានរកឃើញការប្រើប្រាស់ភាសាប្រមាថ គ្រប់ពាក្យមើលងាយ ឬគ្រប់ពាក្យទ្រគោះដោយគ្មានការទំលាក់កំហុស ទោះលើទង្វើណាមួយតាមបច្ចេកវិទ្យាព័ត៌មាន
- មាត្រា៤៩ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី បីឆ្នាំ ទៅ ប្រាំឆ្នាំចំពោះបុគ្គលដែលត្រូវបានរកឃើញការផ្សព្វផ្សាយ ឬការចែកចាយព័ត៌មានមិនពិតតាមបច្ចេកវិទ្យាព័ត៌មាន ដែលមានចេតនាបណ្តាលឱ្យអន្តរាយដល់វិស័យការពារជាតិ សន្តិសុខជាតិ ទំនាក់ទំនងជាមួយប្រទេសដទៃ សេដ្ឋកិច្ច សណ្តាប់ធ្នាប់សាធារណៈ ការរើសអើង និងវប្បធម៌ប្រពៃណីជាតិ

## សេចក្តីព្រាងច្បាប់ស្តីពីសន្តិសុខសាយប័រ

- មាត្រា៤ ផ្តល់អំណាចទូលំទូលាយដល់គណៈកម្មាធិការសន្តិសុខឌីជីថល(គ.ស.ឌ.)
- មាត្រា២១(១)អនុញ្ញាតឱ្យ គ.ស.ឌ. ចូលប្រើ "កុំព្យូទ័រ ឬប្រព័ន្ធកុំព្យូទ័រដែលពាក់ព័ន្ធណាមួយ" អាចប៉ះពាល់ដល់សិទ្ធិឯកជនភាព និងសេរីភាពខាងការបញ្ចេញមតិ។ តើប៉ះពាល់យ៉ាងដូចម្តេច? អាចរងនូវការឃ្លាំមើល និងការដាក់កំហិតខ្លួនឯង។
- មាត្រា ២៤ បង្កើតមន្ត្រីអធិការកិច្ចសន្តិសុខសាយប័រ ដែលត្រូវបានជ្រើសតាំងជា "មន្ត្រីនគរបាលយុត្តិធម៌" ដែលផ្តល់អំណាចយ៉ាងទូលាយ។

## សេចក្តីព្រាងច្បាប់សិទ្ធិទទួលព័ត៌មាន

- មាត្រា២០(៧) មិនបានបញ្ចូលបញ្ញាត្តិដែលជាផលប្រយោជន៍សាធារណៈដើម្បីផ្សព្វផ្សាយព័ត៌មានដាក់លាក់ជាសាធារណៈ

## សេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារទិន្នន័យបុគ្គល

- មាត្រា ៧ (ឃ) (ង) (ច)មានការលើកលែងទូលំទូលាយពេកដើម្បីធ្វើប្រព្រឹត្តកម្មទិន្នន័យ
  - «ផលប្រយោជន៍សាធារណៈ» «ផលប្រយោជន៍ធម្មានុរូប» ឬ «ការពារអាយុជីវិត» ...«រូបវន្តបុគ្គល»
- មាត្រា១៤ (ខ) (ង)(ឆ)មានការលើកលែងទូលំទូលាយពេកដើម្បីធ្វើប្រព្រឹត្តកម្មទិន្នន័យបុគ្គលវេទយិត
- មាត្រា៤ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដើរតួស្ថាប័នត្រួតពិនិត្យការអនុវត្តច្បាប់ ជាជាងគណៈកម្មការទិន្នន័យឯករាជ្យ ស្របតាមឱត្តមានុវត្តន៍អន្តរជាតិ

សម្រាប់ព័ត៌មានបន្ថែម សូមផ្ញើអ៊ីមែលមកកាន់៖ info@cchrcambodia.org
អាសយដ្ឋាន៖ ផ្ទះលេខ ៧៩៨ ផ្លូវលេខ ៩៩ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរសព្ទ៖ +៨៥៥ (០) ២៣ ៧២ ៦៩ ០១

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

CC BY NC SA

ខែវិច្ឆិកា ឆ្នាំ២០២៥